# ទុក្ខោពោធិលះ



ធម្មទេសនារបស់

ព្រះអាចារ្យ ឆា

# ពាក្យប្រារព្ធ

ខ្ញុំបានបោះពុម្ពសៀវភៅនេះឡើងវិញដោយយល់ឃើញថា សព្វថ្ងៃនេះសៀវភៅធម៌ខ្មែរយើងមានការខ្វះខាតជាច្រើន ចំពោះពុទ្ធបរិស័ទដែលមានប្រាថ្នាចង់សិក្សា ចង់ប្រតិបត្តិឲ្យបានជ្រៅជ្រះក្នុងព្រះពុទ្ធសាសនា។ ហេតុនេះហើយ បានជាខ្ញុំខំព្យាយាមបបួលសប្បុរសជនទាំងឡាយបរិច្ចាគធនធាន ចូលរួមក្នុងការបោះពុម្ពសៀវភៅនេះឡើងវិញ ដើម្បីចែកជាធម្មទាន ទុកជាប្រទីបជួយបំភ្លឺផ្លូវដល់លោកអ្នកទាំងឡាយដែលត្រូវការ និងទុកជាធម្មសម្បត្តិក្នុងព្រះពុទ្ធសាសនារបស់ខ្មែរយើងឲ្យបានវែងឆ្ងាយតទៅ។

សូមព្រះពុទ្ធសាសនាបានរីកចម្រើន រុងរឿងពេញសកលលោកទាំងមូល។

សូមឧទ្ទិសភាគផលកុសលនៃការព្យាយាមនេះ សូមឲ្យ ឲ្យខ្ញុំអស់ទៅនៃអាសវៈ ហើយសូមឲ្យបានសម្រេចព្រះនិព្វានជាអវសានជាតិ។

២៥៣៣ / ១៩៩០

ធ្វើនៅអេវរី ថ្ងៃទី ១២ មីនា

ស្រុកបារាំង ដូនជី **ចំរើន ចរូន សុកចម "ចារុវណ្ណា"**

បើលោកអ្នកមានសទ្ធាចូលក្នុងធម្មទាននេះសូមទាក់ទងតាមរយៈ

ដូនជី SOK CHAM 12, SQUARE EINSTEIN

91000 EVRY (FRANCE)

TEL:60.78.16.99

# **កំណត់សម្គាល់អ្នកវាយអត្ថបទ**

ខ្ញុំបានទទួលការពឹងពាក់ពីលោកម្ចាស់មួយអង្គ ដែលព្រះអង្គជាព្រះសង្ឃជនជាតិថៃ ដើម្បីវាយអត្ថបទនេះឡើងវិញ។ ព្រះអង្គបានស្គាល់ខ្ញុំតាមរយៈ ប្លក់ (Blog) របស់ខ្ញុំ ដែលខ្ញុំបានចុះផ្សាយអត្ថបទខ្លះៗអំពីព្រះអាចារ្យ **ឆា** តាមអ្វីដែលខ្ញុំបានអានកន្លងមក។ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង ក្នុងការទទួលភារៈដ៏ល្អប្រពៃនេះ។ ខ្ញុំសង្ឃឹមថា ការខិតខំប្រឹងប្រែងរបស់ខ្ញុំក្នុងការវាយអត្ថបទធម្មទេសនានេះឡើងវិញ នឹងបានជាប្រយោជន៍សម្រាប់ពុទ្ធបរិស័ទទាំងឡាយតទៅ។

អត្ថបទធម្មទេសនា **ទុត្តិយាពោធិលៈ** នេះ ព្រះអាចារ្យ **ឆា** ព្រះអង្គបានសង្កត់ធ្ងន់លើការបដិបត្តិពោលគឺ **បដិបត្តិបូជា** ដែលជាការបូជាដ៏សំខាន់ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនា។ អាមិសបូជាពិតជាសំខាន់ក្នុងការទ្រទ្រង់ព្រះពុទ្ធសាសនាក៏ពិតហើយ តែបដិបត្តិបូជារឹងរឹតតែជាផ្លូវដ៏សំខាន់ក្នុងការទ្រទ្រង់ព្រះពុទ្ធសាសនាឲ្យបានចម្រើនវែងឆ្ងាយតទៅ។

ក្នុងការវាយអត្ថបទនេះឡើងវិញ ខ្ញុំបានកែតម្រូវអក្ខរាវិរុទ្ធដែលខុសឲ្យត្រឹមត្រូវឡើងវិញតាមវចនានុក្រមខ្មែរ (វចនានុក្រម សម្ដេចព្រះសង្ឃរាជ ជួន-ណាត)។ មួយវិញទៀត ខ្ញុំបានសម្រួលនូវឃ្លារបះខ្លះ ដោយដាក់បន្ថែមនូវខណ្ឌសញ្ញាផ្សេងៗ ដើម្បីខណ្ឌឃ្លាក្នុងសង្កាត់នៃប្រយោគឲ្យងាយអានងាយយល់សេចក្តី; ដ្បិតអីអត្ថបទចាស់ទំនងជាវាយតាមរយៈអង្គុលីលេខ ដែលពិបាកក្នុងការគ្រប់គ្រងលើបញ្ហាទាំងអស់នេះ។ ខ្ញុំបានព្យាយាមយ៉ាងយកចិត្តទុកដាក់ ក្នុងការដាក់បន្ថែមនូវខណ្ឌសញ្ញាទាំងនោះ, ធ្វើយ៉ាងណាចៀសវាងមិនឲ្យសេចក្តីល្អៀងពីអត្ថបទដើម។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងដោយអចេតនា ដែលមានក្នុងកិច្ចការវាយអត្ថបទព្រះធម៌ធម្មទេសនានេះឡើងវិញ។

ជាចុងបញ្ចប់នេះ ខ្ញុំសូមលើកឡើងនូវបុណ្យដែលកើតអំពីកិច្ចការជាកុសលនេះ ឧទ្ទិស ថ្វាយប្រគេន ជូន ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ មាតាបិតា បងប្អូន និងញាតិមិត្តទាំងឡាយក្នុងសង្សារវដ្ដនេះ, សូមបាននូវចំណែកបុណ្យកុសលតាមកម្លាំងសទ្ធាជ្រះថ្លារៀងៗខ្លួន។ ដោយអំណាចនៃផលានិសង្សនេះ សូមសេចក្តីសម្រេចចូរកើតមានដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនញាតិមិត្តគ្រប់ៗគ្នា។ សូមឲ្យព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនញាតិមិត្តទាំងអស់, បានរួចផុតចាកទុក្ខ ហើយជួបប្រកបតែនឹងសេចក្តីសុខតរៀងទៅ។ ដោយអំណាចនៃកិច្ចការជាកុសលទាំងឡាយនេះ សូមបានជាឧបនិស្ស័យក្នុងព្រះពុទ្ធសាសនា; ជ្រះថ្លាក្នុងគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដើម្បីបានបណ្ដុះនូវបញ្ញា ហើយចាក់ធ្លុះក្នុងធម៌ ត្រាស់ដឹងនូវព្រះនិព្វានព្វដ៏អនាគតកាល គ្រប់ៗគ្នាគ្រប់ៗព្រះអង្គទៅហោង។

ថ្ងៃអង្គារ ៦កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩

**ហេង រង្សី**

បញ្ជីរាយនាមលោក-អ្នកចូលបច្ច័យជួយបោះពុម្ពសៀវភៅ
ធម្មទេសនាព្រះរាជាគណៈ ឆា

| | |
|---|---|
| ១- ភិក្ខុ **វែម-រិទ្ធី** | ២០០ ហ្វ្រង់ |
| ២- ដូនជី **ចំរើន ពរូន ចារុវណ្ណា** | ២០០ ហ្វ្រង់ |
| ៣- ដូនជី **យន្តៈសីលា សីវ យិន** | ១០០ ហ្វ្រង់ |
| ៤- លោកយាយ **ចំរើន-អឿន** | ១០០ ហ្វ្រង់ |
| ៥- លោកយាយ **រ៉ាវី** | ២៥០ ហ្វ្រង់ |
| ៦- ឧបាសិកា **ប៊ុន-សានិត** | ១៥០ ហ្វ្រង់ |

សូមឥដ្ឋមនុញ្ញផល ដែលកើតអំពីធម្មទាននេះ យើងខ្ញុំសូមឧទ្ទិសជូនដល់លោក-អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ព្រមទាំងញាតិទាំង ៧ សន្តាន ដែលចែកឋានទៅហើយក្តី ឬមានជីវិតរស់នៅសព្វថ្ងៃនេះក្តី ព្រមទាំងយើងខ្ញុំទាំងឡាយនេះផង សូមឲ្យបានជួបតែ សេចក្តីសុខ-ចំរើន ហើយជួបអ្នកមានចិត្តសប្បុរស, កើតជាតិណាៗ សូមមានប្រាជ្ញាយល់ត្រូវ ហើយបានទាន់ស្តាប់ធម៌ទេសនានៃព្រះអរិយមេត្រី បានឆ្លងផុតវាលវដ្តសង្សារ, សូមបានសម្រេចព្រះនិព្វានជាអវសានជាតិ កុំបីឃ្លៀងឃ្លាតទៅជាប្រការដទៃឡើយ។

# ឧត្តោវាទោវាទ

ការជួយទ្រទ្រង់ លើកតម្កើងនូវព្រះពុទ្ធសាសនាដោយចិត្តានុបស្សនា ជាធម៌ទេសនានៃព្រះរាជាគណៈ **ឆា** ព្រះពោធិញ្ញាណ បានប្រែអំពីភាសាសៀម ដោយដូនជី **ចំរើន ចារូន ចារុវណ្ណា**។

ការជួយទ្រទ្រង់ព្រះពុទ្ធសាសនាឲ្យបានចម្រើនតទៅបាននោះ អាស្រ័យហេតុពីរយ៉ាងគឺះ

១- អាមិសបូជា បានដល់ការបូជានូវបច្ច័យបួន មាន **ចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈ** ជាដើមនេះ ជាការជួយទ្រទ្រង់ព្រះពុទ្ធសាសនាដោយការជួយទំនុកបម្រុងដល់ភិក្ខុសង្ឃដែលបដិបត្តិធម៌ គង់នៅក្នុងវត្តឲ្យបានស្រួលផង ដើម្បីលោកជួយទ្រទ្រង់នូវព្រះពុទ្ធសាសនា គឺព្រះធម៌ដែលជាឱវាទ ឬពុទ្ធដីកានៃព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ហើយលោកនឹងជួយពន្យល់ដល់លោក-អ្នកដែលមានសទ្ធាមកបដិបត្តិ។

២- បដិបត្តិបូជា បានដល់ការបូជាដោយការបដិបត្តិ គឺនាំគ្នាធ្វើ **សមាធិភាវនា** និង **វិបស្សនា**។ ភាវនានេះជាផ្លូវដ៏សំខាន់បំផុត ដែលជួយឲ្យព្រះពុទ្ធសាសនាបានចម្រើនតទៅវែងឆ្ងាយ។

ប្រៀបដូចជាដើមឈើមួយដើមដែលមានទាំងឫសគល់ បែកធាង ជាដើម។ ដើមឈើទាំងមូលនេះ អាចរស់នៅបានក៏ដោយអាស្រ័យនូវឫសជាធំ សម្រាប់ស្រូបយកទឹកជាអាហារចិញ្ចឹមដើមទាំងមូលនេះ។ ឯមនុស្សយើងក៏ដូចគ្នាដែរ មានកាយ វាចា ព្រមទាំងអាយតនៈ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ, ទាំងអស់នេះប្រៀបដូចជាដើមឈើ, ឯចិត្តប្រៀបដូចជាឫសដែលសម្រាប់ស្រូបយកអាហារមកចែកដល់ដើមឲ្យចេញជាផ្លែផ្កាមកបាន។ ឯចិត្តមនុស្សយើងក៏ដូចគ្នាដែរ បើកាលណាចិត្តយើងស្ថិតនៅក្នុងការយល់ត្រូវ វានឹងមានការត្រូវ គឺសេចក្តីល្អឲ្យប្រាកដចេញមក។ តែបើចិត្តស្ថិតនៅក្នុងការយល់ខុសវិញ វាក៏សម្តែងការខុសជាសេចក្តីអាក្រក់ចេញមកដែរ គឺចេញមកតាមផ្លូវកាយនិងវាចានេះឯង។

ដូចនេះ ការបដិបត្តិសមាធិនិងវិបស្សនានេះហើយ ដែលជាផ្លូវសំខាន់បំផុត ដែលអាចជួយឲ្យព្រះពុទ្ធសាសនាបានចម្រើនវែងឆ្ងាយតទៅ ហើយនឹងផ្តល់នូវសេចក្តីសុខ-ចម្រើនដល់លោក-អ្នកដែលខំប្រឹងព្យាយាមបដិបត្តិដ៏ពិតប្រាកដទៀតផង។ ប៉ុន្តែមុននឹងយើងចូលទៅរៀនបដិបត្តិសមាធិនោះ ត្រូវមានសីលឲ្យបានបរិសុទ្ធជាមុនសិន ទើបចិត្តរបស់យើងឆាប់បានស្ងប់ល្អ។ នៅពេលដែលយើងទៅសមាទានសីលរាល់ពេលនោះ ព្រះសង្ឃលោកតែងតែក្រើនរម្លឹក ពន្យល់នូវការវៀរចាកអំពើជាអកុសល គឺសេចក្តីអាក្រក់ចោលចេញ ហើយកាន់យកនូវអំពើជាកុសល សេចក្តីល្អវិញ។ យើងបាននាំគ្នាទទួលធ្វើតាមពាក្យដែលព្រះសង្ឃលោកបានទូន្មាននោះជានិច្ច ប៉ុន្តែយើងនាំគ្នាកាន់តែសីលទេ មិនបានព្យាយាមបដិបត្តិសមាធិផង យើងមិនអាចបានទទួលនូវផលប្រយោជន៍ ដ៏ប្រសើរនោះឡើយ។

ការជួយទ្រទ្រង់ព្រះពុទ្ធសាសនា មានតែបដិបត្តិបូជា គឺការភាវនានោះឯង ព្រមទាំងការរក្សាសីលឲ្យទៅជាសីលពិតប្រាកដមែន សមាធិក៏ឲ្យទៅជាសមាធិពិតមែន ដើម្បីឲ្យបានកើតនូវបញ្ញាពិតមែន ទើបយើងអាចយល់បានច្បាស់។ បើកាលណាយើងមិនបានយល់ដោយការបដិបត្តិនោះទេ ស្ង

ម្បីលោក-អ្នករៀនបានចេះចប់ក្នុងព្រះត្រៃបិដកហើយក៏ដោយ ក៏នៅតែមិនយល់។ សម័យព្រះពុទ្ធកាល មានសាវកមួយអង្គនាមថា **ទុត្ថោពោធិលៈ** លោកជាគ្រូដ៏ល្បី មានវត្តសាខា ១៨ វត្ត មានកូនសិស្សជាច្រើនគោរពដល់លោក។ នៅពេលលោកសម្តែងធម៌ គ្មានអ្នកណា-លោកណាអាចចោទឆ្លើយជាមួយនឹងលោកឡើយ ដោយយល់ថា លោកជាអ្នកប្រាជ្ញដ៏ល្បីមួយអង្គ។

មានថ្ងៃមួយ លោក **ទុត្ថោពោធិលៈ** បាននិមន្តទៅក្រាបថ្វាយបង្គំព្រះពុទ្ធជាម្ចាស់។ ព្រះពុទ្ធអង្គបានទ្រង់ត្រាស់សួរទៅកាន់ភិក្ខុ **ពោធិលៈ** ថា "មកហើយឬលោកគម្ពីរទទេ?" លោក **ពោធិលៈ** នឹកឆ្ងល់ ហើយព្រះអង្គទ្រង់ត្រាស់អំពីរឿងផ្សេងៗទៀតតទៅ, ល្មមសមគួរដល់ពេលវេលា ហើយលោក **ទុត្ថោពោធិលៈ** ក៏សូមក្រាបថ្វាយបង្គំលាព្រះសម្ពុទ្ធត្រឡប់ទៅវិញ។ ព្រះអង្គទ្រង់ត្រាស់ទៀតថា "ត្រឡប់ទៅវិញហើយលោកគម្ពីរទទេ?" លោក **ពោធិលៈ** នឹកឆ្ងល់ខ្លាំង ហើយបានយកពុទ្ធដីការបស់ព្រះអង្គទៅពិចារណា ក៏ឃើញពិតប្រាកដមែន ដូចព្រះអង្គទ្រង់ត្រាស់មកនេះ។ លោកគម្ពីរទទេគឺលោក-អ្នកដែលរៀនចេះដឹងច្រើនតែខាងបរិយត្តិ ប៉ុន្តែមិនបានបដិបត្តិ។ បើយើងគិតទៅតាមផ្លូវចិត្តមិនខុសគ្នាអំពីអ្នកស្រុកឡើយ គេចង់បានអ្វី លោកក៏ចង់បាននោះដែរ, គេត្រេកអរនឹងអ្វី លោកក៏ត្រេកអរជាមួយផង, ចិត្តគ្មានធម៌ធ្វើឲ្យស្ងប់រម្ងាប់ឡើយ។ លោកបានគិតពិចារណាដូចនេះហើយ ក៏នឹកចង់ចេញទៅបដិបត្តិខាងសមាធិ ប៉ុន្តែពុំដឹងទៅរកលោកគ្រូណាជួយបង្រៀនបានឡើយ។ លោកបានស្វែងរកគ្រូអាចារ្យជាច្រើន ប៉ុន្តែគ្មានអង្គណាអាចជួយបង្រៀនលោកឡើយ ដោយយល់ថាលោកជាគ្រូអាចារ្យដ៏ល្បីមួយអង្គ។ ម្យ៉ាងទៀត អាចារ្យធំៗជាច្រើនក៏សុទ្ធតែជាកូនសិស្សរបស់លោក **ពោធិលៈ** ទាំងអស់។ នៅទីបំផុត លោកបានទៅសូមរៀនជាមួយលោកនេនតូចមួយអង្គដែលជាអរិយបុគ្គល។ លោកនេនសួរលោក **ពោធិលៈ** ថា "ព្រះគុណម្ចាស់មករៀនជាមួយខ្ញុំករុណា បើមករៀនមែនទែនសឹមមក ប៉ុន្តែបើមករៀនលេងៗទេ កុំមក" លោក **ទុត្ថោពោធិលៈ** ព្រមប្រគល់កាយគោរពធ្វើតាមទាំងអស់។ លោកនេនបានប្រាប់ទៅលោក **ពោធិលៈ** ឲ្យគ្រងចីពរឲ្យបានស្រួល។ ជូននៅជិតហ្នឹងមានកូនបឹងមួយ ដែលលាយទៅដោយភក់។ លោកនេនបានបញ្ជាឲ្យលោក **ពោធិលៈ** ចុះទៅក្នុងបឹងនោះ ហើយប្រាប់ទៀតថា បើកាលណាខ្ញុំមិនទាន់ប្រាប់ឲ្យឈប់ទេ កុំអាលឈប់, បើមិនទាន់ប្រាប់ឲ្យឡើងទេ កុំអាលឡើង។ លោក **ពោធិលៈ** ទើបតែគ្រងចីពររួចស្រួលបួលផង លោកក៏ព្រមចុះទៅក្នុងបឹងដែលមានសុទ្ធតែភក់ជ្រៅទៅៗ។ នេនមិនទាន់ប្រាប់ឲ្យលោកឈប់ លោកក៏មិនហ៊ានឈប់, លុះត្រាតែទទឹកជោកពេញដោយភក់ ហើយទើបលោកនេនប្រាប់ "បានឈប់ចុះ ឡើងមកបាន" លោក **ពោធិលៈ** ឈប់ ហើយឡើងមកវិញ។

លោកនេនបានយល់ថា លោកគ្រូអាចារ្យ **ពោធិលៈ** បានលះនូវទិដ្ឋិអស់ហើយ ទើបលោកធ្វើតាមបញ្ជាទាំងអស់នេះ។ លោកនេនបានឃើញឧបនិស្ស័យរបស់លោក ដែលមកខំបដិបត្តិពិតប្រាកដមែនទែនហើយ ទើបលោកនេនចាប់ផ្តើមបង្រៀនតាមវិធីកំណត់មើលអារម្មណ៍ ដែលកើតរលត់ ឲ្យចាំមើលចិត្តរបស់ខ្លួន ឲ្យស្គាល់អារម្មណ៍របស់ខ្លួនជានិច្ច។ ការកំណត់នៅលើដង្ហើមចេញនិងចូលនេះ ឲ្យមានសតិទៅជាមួយផង គឺពេលដកដង្ហើមវែងឬខ្លី ខ្លាំងឬតិច គ្រោធគ្រោធឬល្អិត, ឲ្យមានសតិដឹងសព្វ។ សតិ គឺការដឹងទាន់នូវការកម្រើកនៃឥរិយាបថបួន ដេក ឈរ ដើរ អង្គុយ។ រវាំង

ឲ្យដឹងថា ឥឡូវនេះយើងកំពុងធ្វើអ្វី, សម្បជញ្ញៈគឺការដឹងថា យើងកំពុងធ្វើនេះធ្វើនោះ។ បើនៅពេលទំនេរ មិនបានធ្វើអ្វីទេ ត្រូវព្យាយាមពិនិត្យមើលដង្ហើមចូលនិងដង្ហើមចេញ ឲ្យមានសតិនូវការរឭកបាន ការចាំបាន។

លោកនេនបានលើកយកចំណុចមួយថាឲ្យប្រើវិធីអ្នកទៅចាប់សត្វទន្សង។ នៅពេលគេចង់ចាប់វា គេតែងតែទៅបិទរន្ធដែលវាចេញចូល តែងមានច្រើនរន្ធ, ត្រូវបិទឲ្យអស់នូវរន្ធឯទៀត ទុកតែរន្ធមួយបានហើយ ហើយនៅរង់ចាំមើលមាត់រន្ធនោះយ៉ាងប្រុងប្រយ័ត្នបំផុត។ មិនយូរប៉ុន្មានសត្វទន្សងនោះនឹងចេញមកតាមរន្ធនោះឯង, គេអាចចាប់វាបានដោយស្រួល។ យ៉ាងណាមិញ អ្នកដែលបដិបត្តិសមាធិក៏ដូចគ្នាដែរ។ នៅពេលអង្គុយសមាធិ ត្រូវព្យាយាមបិទអាយតនៈឯទៀតឲ្យអស់ ទុកតែមួយ គឺកំណត់នូវការដកដង្ហើមចូលនិងដង្ហើមចេញ និងចាំមើលចិត្តបានហើយ គឺខំសង្រួមសំវរឲ្យកំណត់មើលចិត្ត។

ការភាវនាក៏ដូចគ្នានឹងអ្នករកចាប់ទន្សងដែរ។ ដូចជាយើងកំណត់នៅលើដង្ហើម ឲ្យមានសតិនៅជាមួយជានិច្ច, សម្បជញ្ញៈគឺការដឹងថា យើងកំពុងធ្វើនេះធ្វើនោះ។ បើនៅពេលទំនេរមិនបានធ្វើអ្វីទេ ត្រូវអង្គុយមើលដង្ហើមចូលនិងចេញ ដោយមានសតិ ការរឭកបាន ការចាំបាន គឺសេចក្ដីដឹងដែលកើតអំពីចិត្ត មិនមែនទៅខំរករៀនពីណាមកទេ, ឲ្យស្គាល់តែការដឹងដែលកើតអំពីចិត្ត ចិត្តដែលកំពុងនៅស្ងៀម ស្រាប់តែមានសេចក្ដីនឹកគិតអ្វីកើតឡើង នេះហើយដែលជាសេចក្ដីដឹងរបស់ចិត្ត។ សតិនេះជាអ្នកចាំឃ្លាំមើល គឺដឹងទាន់ថា យើងកំពុងនិយាយ កំពុងធ្វើការងារផ្សេងៗ កំពុងដើរឬកំពុងអង្គុយ ដើរទៅមកក៏ឲ្យដឹងទាន់ នេះហៅថាសតិ, ដឹងបានដោយសម្បជញ្ញៈ គឺការដឹងខ្លួនជានិច្ច នៅពេលនេះយើងកំពុងដេក កំពុងដើរ កំពុងអង្គុយ ឬយើងកំពុងទទួលអារម្មណ៍អ្វីក្នុងពេលនេះ។ ទាំងពីរយ៉ាងនេះគឺ **សតិ** ការដឹងទាន់ និង **សម្បជញ្ញៈ** មិនភ្លេចខ្លួន, ដឹងខ្លួនក្នុងការដែលយើងធ្វើ រឭកទាន់ជានិច្ច។ នេះហើយយើងអាចស្គាល់ចិត្តរបស់យើងថាក្នុងពេលនេះវាកំពុងគិតអ្វីខ្លះ បើប៉ះអារម្មណ៍បែបនេះមកវាគិតយ៉ាងណា។ ដូចនេះ យើងអាចនឹងស្គាល់ចិត្តរបស់យើងបានច្បាស់ដោយមានសតិជាប់ជានិច្ច។

អ្នកដែលទទួលដឹងនូវអារម្មណ៍នោះគឺ **ចិត្ត**។ **អារម្មណ៍** គឺសភាវៈដែលចូលមក ដូចជាមានសំឡេងកង្កែបយំ វាចូលមកតាមត្រចៀក ចិត្តក៏ទទួលដឹងថាជាសំឡេងរបស់កង្កែបយំ។ អ្នកដែលទទួលដឹងនូវអារម្មណ៍ដែលថាជាសំឡេងកង្កែបយំបាននោះហៅថាចិត្ត។ នៅពេលនេះ ចិត្តដែលទទួលនោះជាចិត្តដែលគ្រោតគ្រាត ជាចិត្តដែលកើតឡើងជាប្រក្រតីរបស់ចិត្ត។ ជួនកាលយើងអង្គុយស្ដាប់សំឡេងកង្កែបវាយំ កើតសេចក្ដីធុញទ្រាន់ក្នុងសេចក្ដីដឹងនោះឡើង។ យើងត្រូវអប់រំដល់អ្នកទទួលដឹងនោះម្ដងទៀត គឺឲ្យដឹងតាមការពិតដែលហៅថា **ពុទ្ធោ**។ បើកាលណាមិនបានដឹងតាមការពិតទេ នឹងអាចធុញទ្រាន់នឹងសំឡេងនោះៗ, ដូចជាសំឡេងមនុស្សឬសំឡេងឡានបើកបរ សំឡេងសត្វយំជាដើម មានតែចិត្តដែលកំពុងស្ងប់ស្ងៀមនេះហើយ ជាអ្នកធុញទ្រាន់។ នេះគឺដឹងទៅតាមសញ្ញា មិនមែនដឹងតាមការពិតឡើយ។ យើងត្រូវឲ្យដឹងតាមញាណទស្សនៈ គឺអំណាចរបស់ចិត្តដែលល្អិត ត្រូវឲ្យដឹងថា សំឡេងកង្កែបដែលកំពុងយំឮសូរខ្លាំងនេះ គឺគ្រាន់តែជាសំឡេងប៉ុណ្ណោះ។

បើសិនជាកុំទាញយកមកដាក់ក្នុងចិត្តនោះទេ យើងក៏គ្មានសេចក្ដីធុញទ្រាន់ក្នុងសំឡេងនោះឡើយ។ សំឡេងដែលឮនោះតាមតែវាទៅចុះ យើងក៏អាចអង្គុយស្ដាប់បានតទៅដោយស្រួល, យ៉ាងនេះហៅថា **សេចក្ដីដឹងក្នុងអារម្មណ៍ដែលកើតឡើង**។ តែបើយើងភាវនា **ពុទ្ធោ** យើងមានសេចក្ដីដឹងច្បាស់នូវអារម្មណ៍ដែលកង្អែបយំ ប៉ុន្តែសំឡេងនេះមិនបានធ្វើឲ្យយើងរំខានដល់អ្នកណាឡើយ, វាឮសូរតាមតែសភាវៈ។ សំឡេងនេះមិនមែនសត្វ មិនមែនបុគ្គល មិនមែនខ្លួនប្រាណរបស់យើងគេទេ គឺជាសំឡេងតែប៉ុណ្ណោះ, យើងអាចឈប់គិតអ្វីទាំងអស់។ បើយើងបានយល់យ៉ាងនេះហើយ គឺចិត្តដឹងតាមសភាវៈ ដែលហៅថា **ពុទ្ធោ** នេះឯង។ ការយល់ច្បាស់ធ្វើឲ្យកើតនូវសេចក្ដីរីករាយ ដោយបានដឹងតាមការពិតដែលកើតឡើងនេះ, សំឡេងក៏គ្រាន់តែសំឡេង មិនបានទៅធ្វើឲ្យអ្នកណាធុញទ្រាន់រំខានឡើយ។ បើយើងកុំទៅទាញយកមក គឺថា យើងធុញទ្រាន់ណាស់ មិនចង់ឮអ្នកនេះនិយាយដូច្នេះសោះ មិនចង់ឮសំឡេងនេះ មិនចង់ឮសំឡេងនោះជាដើម, ដូច្នេះយើងទៅជាកើតទុក្ខឡើង។

ហេតុដែលយើងកើតទុក្ខនេះ កើតមកពីព្រោះអ្វី? ពីព្រោះតែយើងមិនដឹងនូវការពិតរបស់វា, នៅមិនទាន់បានភាវនា **ពុទ្ធោ** មិនទាន់ជាក់ច្បាស់ មិនទាន់ភ្ញាក់រឭក, មិនទាន់បានស្គាល់; មានតែចិត្តដែលមិនទាន់បានអប់រំឲ្យបរិសុទ្ធ ជាចិត្តដែលមិនទាន់ប្រើការអ្វីបាន។ ដូចនេះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថាឲ្យនាំគ្នាខំព្យាយាមបដិបត្តិ ដើម្បីឲ្យចិត្តមានកម្លាំងមាំទាំ។ ការធ្វើចិត្តឲ្យមានកម្លាំងនិងការធ្វើកាយឲ្យមានកម្លាំងនេះ មានលក្ខណៈដូចគ្នា, ប៉ុន្តែមានវិធីខុសគ្នា។ ការហាត់ប្រាណ (កាយ) ឲ្យមានកម្លាំងនោះ គឺយើងត្រូវកម្រើកនូវអវយវៈ ដោយការរឹត ច្របាច់ ឬរត់នៅពេលព្រឹកៗ ជាដើមនេះហៅថា ធ្វើកាយឲ្យមានកម្លាំង មានសុខភាពល្អ មានការរវៀសរវៃឡើង ឈាមរត់ស្មើសព្វទៅតាមសរសៃបសាទបានស្រួល គឺកាយរបស់យើងនឹងបានស្រួលជាងពេលដែលមិនទាន់បានទៅហាត់។ ប៉ុន្តែការហាត់ចិត្តឲ្យមានកម្លាំងនេះ មិនមែនឲ្យវារត់នោះទេ; មិនមែនឲ្យវាកម្រើកដូចជាហាត់ប្រាណនោះឡើយ គឺធ្វើចិត្តឲ្យវាឈប់ ឲ្យចិត្តបានសម្រាកដូចជាយើងធ្វើសមាធិ, លើកយកនូវអារម្មណ៍មួយណាមកបរិកម្មដូចជាអានាបាណស្សតិ យកដង្ហើមចេញចូលមកធ្វើជាអារម្មណ៍ ជាបង្គោល ជាចំណុចក្នុងការសង្កេតពិចារណា។ យើងកំណត់មើលខ្យល់ចេញចូល; ការកំណត់នេះ គឺការដឹងក្នុងពេលដកដង្ហើមចូល-ចេញ តាមធម្មតា ហើយព្យាយាមលះបង់នូវអ្វីៗទាំងអស់ចេញ។ ចិត្តរបស់យើងនិងមានកម្លាំងស្រួល ដោយមានអារម្មណ៍តែមួយ។ តែបើយើងបណ្ដោយចិត្តឲ្យគិតនេះគិតនោះគ្រប់យ៉ាង អារម្មណ៍មានច្រើន វាមិនអាចនៅរួមជាអារម្មណ៍តែមួយបាន ចិត្តរបស់យើងមិនអាចស្ងប់បានឡើយ។

ដែលហៅថា **ចិត្តស្ងប់** នោះគឺ វាស្ងប់ក្នុងការដឹង, មិនបែកចេញទៅគ្រប់កន្លែង ដូចជាយើងមានកាំបិតមួយ ដែលយើងបានសំលៀងយ៉ាងមុតហើយ ហើយយើងយកទៅកាប់ថ្ម ឥដ្ឋ ស្មៅគ្រប់យ៉ាងដោយឥតរើសមុខ; យ៉ាងនេះឃើញថា កាំបិតរបស់យើងនេះ ឈប់មុតទៀតហើយ។ ហេតុនេះត្រូវកាប់ឆ្ការតែរបស់ណាដែលជាប្រយោជន៍ដល់យើង។

ឯចិត្តនេះក៏ដូចគ្នាដែរ។ បើយើងបណ្ដោយចិត្តឲ្យចេញទៅជាប់ជាមួយរបស់ដែលឥតប្រយោជន៍ យើងក៏មិនបានទទួលប្រយោជន៍អ្វីឡើយ; ចិត្តឥតមានកម្លាំង មិនបានសម្រាក។ កាល

ណាចិត្តឥតកម្លាំងហើយ បញ្ញាក៏មិនអាចកើតបានដែរ។ ចិត្តដែលឥតមានកម្លាំងនោះ គឺចិត្តដែលគ្មានសមាធិសោះ។ កាលណាចិត្តមិនបានស្ងប់ហើយ យើងមិនអាចមើលអ្វីឲ្យបានច្បាស់ឡើយ។ បើយើងស្គាល់ចិត្តនោះគ្រាន់តែជាចិត្ត អារម្មណ៍ក៏គ្រាន់តែជាអារម្មណ៍ប៉ុណ្ណោះ; នេះជាជំហានទីមួយដែលយើងត្រូវយល់ ក្នុងការបដិបត្តិនៃព្រះពុទ្ធសាសនា, នេះហើយជាអង្គសាសនា។ យើងធ្វើចិត្តឲ្យបានសប្បាយ សុខដោយការបដិបត្តិ ឲ្យទៅជា **សមថ** និង **វិបស្សនា** រួមគ្នាមកទៅជា **សមថវិបស្សនា**; ជាឧបដិបត្តិអប់រំចិត្តឲ្យនៅក្នុងសីលធម៌ ឲ្យចិត្តបានស្ងប់ ឲ្យចិត្តកើតបញ្ញា ឲ្យដឹងទាន់តាមការពិតរបស់វាជានិច្ច។ បើនិយាយតាមការពិត ដូចជាយើងកើតមកជាមនុស្ស, ការដែលយើងរស់នៅការបរិភោគ ដំណើរជីវិតដែលប្រព្រឹត្តទៅរាល់ថ្ងៃនេះ យើងប្រៀបបាននឹងក្មេងតូច។ ក្មេងតូចវាមិនយល់អ្វីសោះទេ។ បើមនុស្សចាស់មកអង្គុយមើលវាលេង វាតែងតែហាក់លោត, នោះគ្មានបានប្រយោជន៍អ្វីទេ។ ឯចិត្តរបស់យើងដែលមិនទាន់បានអប់រំក៏ដូចគ្នាដែរ; ជាចិត្តដែលខ្សោយ បើនឹងនិយាយស្តីអ្វីៗក៏គ្មានសតិ, ធ្វើការអ្វីក៏មិនសូវមានបញ្ញា, របស់ដែលទ្រុឌទ្រោមទៅក៏យើងមិនដឹងរបស់ដែលត្រូវវិនាសទៅវិញក៏យើងមិនដឹង។ ចេះតែនាំគ្នាលេងទៅៗ ដូចជាក្មេងតូច; នេះគឺចិត្តដែលមិនទាន់បានអប់រំ។ ដូច្នេះហើយបានជាយើងត្រូវតែខំអប់រំចិត្តរបស់យើង។ ព្រះពុទ្ធជាម្ចាស់លោកបានទ្រង់ត្រាស់ថាឲ្យយើងនាំគ្នាអប់រំចិត្តនេះ ហាត់ពត់ចិត្តនេះឲ្យមែនទែន។ សូម្បីយើងខំជួយព្រះពុទ្ធសាសនា ក្នុងបច្ច័យបួនក៏ដោយ ក៏គ្រាន់តែជារបស់ខាងក្រៅប៉ុណ្ណោះ, ជាសំបក។ ការជួយទំនុកបម្រុងព្រះពុទ្ធសាសនាពិតមែននោះ នៅត្រង់ការខិតខំបដិបត្តិនេះហើយ; គ្មានអ្វីក្រៅពីការដែលយើងខំបដិបត្តិសព្វថ្ងៃនេះទេ។ ការខំព្យាយាមអប់រំកាយវាចាចិត្តរបស់យើងនេះ ហៅថា **ការប្រព្រឹត្តបដិបត្តិ** ដែលអាចចែកចេញទៅបានច្រើនផ្លូវទៀត។ បើមនុស្សយើងមានសេចក្តីស្មោះត្រង់ មានសេចក្តីសុចរិត មានសីលធម៌, ការបដិបត្តិតទៅខាងមុខ ក៏នឹងបានផលល្អជាមិនខាន; គ្មានការច្រណែន គ្មានការព្យាបាទដល់គ្នាឡើយ នេះហើយដែលព្រះពុទ្ធទ្រង់បង្រៀនឲ្យធ្វើ។

យើងត្រូវចូលចិត្ត យល់ឲ្យច្បាស់នូវការមកសូមសមាទានសីលនេះ។ យើងត្រូវនាំគ្នាខំព្យាយាមបដិបត្តិថែមទៀត ទើបបានយល់នូវការពិត ក្នុងរូបកាយរបស់គេយើងរាល់គ្នានេះ, គ្រាន់តែជាដុំធាតុទេ។ កាលណាយើងមិនបានបូជាដោយការបដិបត្តិនេះទេ យើងមិនអាចដល់នូវ **ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ** រហូតមួយជីវិតក៏សឹងមាន, ឬពោលដោយងាយៗថា យើងមិនទាន់ចូលដល់ព្រះពុទ្ធសាសនាក៏បាន។ ដូចជាផ្លែឈើមួយយ៉ាង ដែលគេនាំគ្នាពោលថា វាផ្អែម វាជូរ វាខ្ចិះ, តែបើយើងមិនបានបរិភោគទេនោះ ក៏គ្មានបានកើតប្រយោជន៍ គឺបានដឹងជាតិរស់នៃផ្លែឈើនោះឡើយ។ សូម្បីវាមានជាតិឆ្ងាញ់វិសេសយ៉ាងណាក៏ដោយ យើងគ្មានដឹងការពិតក្នុងជាតិរបស់ផ្លែឈើនោះឡើយ។ ក្នុងព្រះពុទ្ធសាសនាក៏ដូចគ្នាដែរ។ បើយើងមិនបានភាវនា យើងក៏មិនបានដឹងក្នុងរឿង **ទាន សីល** និង **ភាវនា** ឡើយ។

ដូចនេះ ការបដិបត្តិជាកូនសោមួយ គឺកូនសោភាវនា។ ឯមេសោនោះជាអ្វីក៏ដោយចុះ; យើងកាន់កូនសោជាប់នៅក្នុងដៃរបស់យើង ទោះបីវាបិទជិតណែនយ៉ាងណាក៏ដោយចុះ, បើយើងយកកូនសោទៅចាក់ពេលណា ត្រូវបើកក្នុងពេលនោះ។ ប៉ុន្តែបើមានតែមេសោ ហើយគ្មានកូនសោនោះទេ

សូម្បីមានរបស់ល្អវិសេសនៅក្នុងហិបជិតយើងក៏ដោយ  ក៏យើងមិនអាចបើកយកបានដែរ។  ហេតុនេះហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឲ្យយើងរៀនឲ្យបានដឹងរបស់ទាំងអស់នេះ;  នាំគ្នាខំព្យាយាមបដិបត្តិ សមថនិងវិបស្សនានេះ។ សេចក្តីចេះដឹងនេះមានពីរយ៉ាង គឺអ្នកដែលចេះធម៌នោះ, លោកមិនបានយកនូវការចាំមកនិយាយទេ  តែលោកយកការចេះពិតមកនិយាយ។  មនុស្សខាងផ្លូវលោក គេយកការចេះចាំមកនិយាយ ហើយនាំគ្នានិយាយតាមបែបភ្ញាក់ផ្អើល។ ដូចជាបែកគ្នាយូរមកហើយ ដោយទៅនៅឯបរទេស ឬទៅនៅស្រុកខេត្តណាឆ្ងាយៗ; មានពេលមួយ ដើរទៅជួបគ្នា "យី! ខ្ញុំសប្បាយចិត្តណាស់  ខ្ញុំគិតថានឹងទៅលេងនៅពេលឆាប់ៗនេះ",  តែការពិតគ្មានបាននឹកគិតទេ។ នេះជាពាក្យមិនពិតសោះ  ប៉ុន្តែខំតែងបង្កើតពាក្យនេះភ្លាមៗមក។  ដោយត្រេកអរនឹងការបានជួបគ្នាក៏នឹកនិយាយពាក្យនេះក្នុងបច្ចុប្បន្ននោះឡើង។ នេះជាពាក្យកុហកមួយ  គឺកុហកដោយមិនដឹងខ្លួន។ ការពិតមិនបានគិតថានឹងទៅលេងទេ កុហកបែបនេះក៏មានខ្លះដែរ។ នេះជាកិលេសមួយ គឺមិនមែនការពិតក្នុងពាក្យដែលយើងពោលចេញមកក្នុងពេលនេះ ប៉ុន្តែគេខំតាក់តែងធ្វើទៅបាន។ នេះជាការកុហកមួយយ៉ាងល្អិត ហើយមនុស្សភាគច្រើនចូលចិត្តនិយាយគ្នាបែបនេះឯង។

ដូចនេះ រឿងចិត្តនេះ លោក **ទុត្ឆោពោធិលៈ** បានធ្វើតាមលោកនេនប្រាប់ឲ្យដកដង្ហើមចូល-ចេញ ហើយពិចារណាមើលសតិ ឲ្យមានសម្បជញ្ញៈ មានការដឹងព្រមជុំវិញ, ទើបអាចចាប់បាននូវការកុហករបស់វា  គឺការកុហកនូវចិត្តរបស់ខ្លួនឯង,  ឃើញកិលេសទាំងអស់ដែលវារចេញមក  ដូចសត្វទន្សងដែលចេញអំពីរន្ធ គ្រាន់តែវាអើតក្បាលចេញមក យើងឃើញវាភ្លាម; តែប៉ុណ្ណោះវាចប់រឿងទៅហើយ។ បន្តិចវាបង្កើតតាក់តែងអ្វីឡើងមកទៀត; ម្តងគិតយ៉ាងនេះ ម្តងវាគិតយ៉ាងនោះ, ជួនកាលគិតបែបថ្មីមកទៀត គិតរឿងផ្សេងៗមកទៀត។ ការគិតរបស់យើងជាសង្ខតធម៌ គឺបច្ច័យតាក់តែងឲ្យកើតឡើង មិនមែនអសង្ខតធម៌ គឺរបស់ដែលមិនមានបច្ច័យតាក់តែងនោះទេ។ ចិត្តដែលបានអប់រំល្អហើយ  មានសេចក្តីដឹងល្អហើយ,  អារម្មណ៍មិនអាចតាក់តែងបានឡើយ;  មិនមែនជឿអ្នកណា  គឺត្រាស់ដឹងដោយការពិត  ហៅថា **អរិយសច្ច**។ ដឹងដោយអរិយសច្ច គឺដឹងនូវការពិត, អារម្មណ៍វានឹងបញ្ឆោត  ធ្វើកលមាយាថារបស់នេះល្អ  របស់នោះមិនល្អ  យ៉ាងនេះក៏ដោយចុះ;  បើកាលណាយើងមាន  **ពុទ្ធោ**  នៅក្នុងចិត្តហើយ  អារម្មណ៍មិនអាចមកកុហកយើងបានទៀតឡើយ  គឺយើងស្គាល់ចិត្តតាមការពិតរបស់វាហើយ។  ដូចនេះ  អារម្មណ៍មិនអាចមកតាក់តែងទៀតបានទេ។  នៅពេលឃើញអារម្មណ៍ ក៏ដឹងថាជារបស់មិនទៀង អារម្មណ៍នេះវាជាទុក្ខ។ អ្នកដែលនៅជាប់នៅនឹងអារម្មណ៍នោះក៏នឹងជាទុក្ខ  ពីព្រោះអារម្មណ៍នោះ  វាជាសភាពមិនទៀតមកហើយ។  ដូចនេះ  បើយើងនឹងទៅនៅទីណាកន្លែងណាក៏ដោយ អ្នកដែលចេះដឹងនឹងគិតដូច្នេះ។ លោក **ទុត្ឆោពោធិលៈ** ក៏បានដឹងដូច្នេះ គឺលោកតាមមើលនូវអារម្មណ៍ដែលកើតឡើងជាមួយនឹងចិត្ត; មើលចិត្តដែលប្រព្រឹត្តទៅ វាកុហកច្រើនយ៉ាង, លោកក៏បានដឹងរឿងរបស់វា។ ចាប់ខ្លួនកុហកបានថា ឱ! អានេះទេតើជាមេកុហក; នេះហើយជាតួសំខាន់,  អានេះហើយវានាំយើងឲ្យសប្បាយត្រេកអរឡើងភ្លេចខ្លួន  ហើយវានាំយើងឲ្យកើតទុក្ខព្រួយ  ចង់ទៅជាឈឺ  ចង់ខូចសតិ  ចង់ទៅជាឆ្កួត  ហើយឲ្យយើងនៅវិលវល់ក្នុងវាលវដ្តសង្សារនេះ។ ទាំងសុខទាំងទុក្ខ ល្អ អាក្រក់ រហូតមកដល់ឥលូវនេះ ពីព្រោះអាមេសំខាន់នេះឯង។ លោក **ពោធិលៈ**

ក៏បានដឹងរឿងរបស់ទាំងនេះអស់ ហើយលោកក៏ចាប់ខ្លួនកុហកបាន ដូចជាបុរសចាប់ទន្សងដូច្នេះដែរ គឺចាប់បានត្រង់ចំណុចសំខាន់របស់វាបាន។ យើងនេះក៏ដូចគ្នាដែរ មានចិត្តនេះហើយជាមេសំខាន់ ជាមេនាំមុខ។ ដូច្នេះហើយបានជាព្រះពុទ្ធអង្គទ្រង់ត្រាស់ឲ្យយើងខំអប់រំចិត្តឲ្យបានល្អផ្ចិតផ្ចង់។

ចិត្តគឺហៅថា ចិត្ត; តើនឹងយកអ្វីមកអប់រំវាទៀត? ចិត្តនេះបើយើងមានសតិ មានសម្បជញ្ញៈខ្ជាប់ខ្ជួនល្អហើយ យើងអាចស្គាល់ចិត្តបាន។ អ្នកដែលស្គាល់ចិត្តនេះ គឺនៅពីលើចិត្ត ដឹងពីលើចិត្ត។ នេះហើយហៅថា **អ្នកដឹងស្គាល់ចិត្តបាន** គឺអ្នកស្គាល់សភាវៈរបស់ចិត្តនោះ ចិត្តនេះក៏ជាចិត្ត។ នេះហើយហៅថា **អ្នកដឹង** គឺអ្នកដឹងស្គាល់ជាងចិត្តរបស់យើងទៅទៀត; ទើបអាចតាមរក្សាចិត្តរបស់ខ្លួនបាន ហើយអាចបង្រៀននូវចិត្តរបស់ខ្លួនឲ្យដឹងថា ធ្វើនេះខុស ធ្វើនេះត្រូវ។ នៅទីបំផុត បើនិយាយតាមធម្មជាតិ វានៅធំលើចិត្តនេះហើយ។ មនុស្សយើងនេះ ស្រេចលើចិត្តជាអ្នកតាក់តែងរឿងរ៉ាវគ្រប់យ៉ាង។ បើកាលណាវាតាក់តែងទៅតាមផ្លូវណាហើយ បើគ្មានរបស់អ្វីអាចដឹងឲ្យបានជាងចិត្តនេះទេ ចិត្តនោះក៏ទៅជាជាប់ជំពាក់។ ដូចនេះ អាស្រ័យចិត្តនេះហើយ ជាអ្នកចាំស្តាប់ តាមរាំងមើល ទើបលោកហៅថា **ពុទ្ធោ** បានដឹងច្បាស់ ដឹងសព្វ, បានរីករាយរហូត, បានដឹងដល់ទីបំផុត ដឹងជាងចិត្តរបស់យើងទៅទៀត ដឹងរឿងរ៉ាវរបស់ចិត្តគ្រប់យ៉ាង។ ដូចនេះ បានជាព្រះពុទ្ធអង្គទ្រង់ត្រាស់ឲ្យយើងខំព្យាយាមអប់រំចិត្តឡើង គឺភាវនាយកពុទ្ធោមកជាអារម្មណ៍មកបរិកម្មឲ្យបានស្គាល់ចិត្ត ឲ្យនៅពីលើចិត្ត ខ្ពស់ជាងចិត្ត; ឲ្យគ្រាន់តែដឹងថា ចិត្តនេះគិតទៅណា ទៅផ្លូវល្អឬទៅផ្លូវអាក្រក់ក៏ដោយ គឺឲ្យអ្នកដែលដឹង ដែលស្គាល់ចិត្តនេះគិតថា ឱ! នេះគ្រាន់តែជាចិត្តទេ។ វាកើតតាមរឿងរបស់វាយ៉ាងដូច្នេះឯង; មិនមែនបុគ្គល ខ្លួនប្រាណ យើងគេទេ, នេះហៅថា **ចិត្តានុបស្សនា**។ កាលបើឃើញយ៉ាងនេះហើយ ចិត្តនឹងនៅជា **អនិច្ចំ ទុក្ខំ អនត្តា**; ចិត្តនេះក៏នៅតែមិនទាន់ជារបស់យើងទៀត នៅមានកុហកយើងបានទៀត, កុំទុកចិត្តវាឡើយ។ បង្រួមសេចក្តីថា ចិត្តជាអ្នកទទួលដឹងនូវអារម្មណ៍, អារម្មណ៍ក៏ជាអារម្មណ៍ ចិត្តក៏ជាចិត្ត។ អ្នកដែលទទួលដឹងអំពីចិត្តនិងអារម្មណ៍នោះ វានៅធំជាងចិត្ត នៅពីលើអារម្មណ៍ទៅទៀត, វាប្រព្រឹត្តទៅយ៉ាងនេះ។ ហើយមានវត្ថុមួយអាចជួយលាងជុះខាត់ចិត្តបាននោះលោកហៅថា **សតិ**; សតិនេះតែងមាននៅគ្រប់គ្នាទាំងអស់។ ឆ្មាក៏មានសតិនៅពេលដែលវាចង់ចាប់កណ្តុរស៊ី, ឆ្កែក៏វាមានសតិ នៅពេលដែលវាព្រុសឬខាំមនុស្ស; ទាំងអស់នេះហៅថា សតិដែរ ប៉ុន្តែមិនមែនហៅថាជាសតិតាមផ្លូវធម៌ទេ។

មនុស្សទាំងអស់គ្នាសុទ្ធតែមានសតិ ដូចគ្នានឹងរាងកាយដែរ។ សូមឲ្យយើងពិចារណានូវរាងកាយរបស់យើង។ "តើឲ្យពិចារណាអ្វីកាយនេះ? អ្នកណាដែលមិនឃើញ ដូចជា **កេសា** ក៏ឃើញ, **នខា** ក៏ឃើញ, **ទន្តា** ក៏ឃើញ; គឺសក់ រោម ក្រចក ធ្មេញ ស្បែក ឃើញទាំងអស់ហើយ, តើនឹងឲ្យឃើញអ្វីទៀត?" នេះហើយមនុស្សយើងវាយ៉ាងនេះឯង; ឃើញហើយ ប៉ុន្តែមិនបានឃើញឲ្យដល់ជម្រៅរបស់វា, មិនបានឃើញដោយ **ពុទ្ធោ** អ្នកដែលភ្ញាក់រឭកហើយ គឺឃើញដោយតាមធម្មជាតិ គឺឃើញកាយក្នុងកាយ; ឃើញកាយតែខាងក្រៅក៏មិនទាន់គ្រប់គ្រាន់ដែរ។ បើកាលណាឃើញកាយធម្មតានាំឲ្យវិនាស។ សូមឲ្យឃើញកាយក្នុងកាយ ចូលទៅមួយស្រទាប់ទៀត ទើបបានយល់ច្បាស់

ឡើង។ បើកាលណាឃើញតែរាងកាយខាងក្រៅ អាចធ្វើឲ្យវង្វេង គឺនៅជាប់ចិត្តស្រលាញ់នូវរូបនោះ ថាស្អាត ថាមិនស្អាត; មិនឃើញអនិច្ចំ ទុក្ខំ អនត្តាឡើយ។ ហើយកើតទៅជាកាមច្ឆន្ទៈ នៅជាប់ជំពាក់នឹង **រូប សំឡេង ក្លិន រស សម្ផស្ស**។ អ្នកឃើញរាងកាយដុំនេះ កាលណាមើលតាមភ្នែកធម្មតា ឃើញតែអំពីស្រលាញ់អ្នកនេះ ស្អប់អ្នកនោះ អានេះល្អ អានោះមិនល្អ ជាដើម។ ព្រះពុទ្ធអង្គទ្រង់បង្រៀនថា បែបនេះមិនទាន់គ្រប់គ្រាន់ទេ ត្រូវឲ្យឃើញដោយភ្នែករបស់ចិត្តម្តងទៀត; ឲ្យឃើញកាយក្នុងកាយ។ បើឃើញកាយក្នុងកាយហើយ តើឃើញមានអ្វីខ្លះនៅក្នុងកាយនោះ? ឱ! មិនគួរមែនសោះ; របស់ថ្ងៃនេះក៏មាន កាលពីម្សិលមិញក៏នៅមាន, មិនដឹងជាស្អីខ្លះទេ។

ដូចនេះ យើងត្រូវមើលឲ្យបានហ្មត់ចត់ ជ្រៅជាងការណ៍ដែលឃើញដោយភ្នែកធម្មតា; ពិចារណាឲ្យឃើញដោយភ្នែករបស់ចិត្ត ដោយបញ្ញាចក្ខុ ឃើញដោយបញ្ញា, ការណ៍ដែលឃើញនោះវាប្លែកគ្នាយ៉ាងនេះឯង។ អ្នកខ្លះបង្រៀនឲ្យពិចារណា **កេសា លោមា នខា តចោ**; ក៏មិនយល់ថា មិនដឹងជាឲ្យពិចារណាធ្វើអ្វី សក់ រោម ក្រចក ធ្មេញ ស្បែក, វាស្គាល់អស់ហើយ; តែវាមិនឃើញដល់ការពិត ឃើញត្រឹមតែផ្នែកក្រៅប៉ុណ្ណោះ។ អាភ្នែកឆ្កួតនេះ វាឃើញសុទ្ធតែល្អៗ; របស់ណាដែលកខ្វក់ស្មោកគ្រោក វាមិនឃើញទេ។ ពាក្យដែលថា ឃើញកាយក្នុងកាយនេះ គឺឲ្យឃើញច្បាស់ទៅដល់ខាងក្នុងមួយថ្នាក់ទៀត ហើយពិចារណាឲ្យយល់នូវការពិតរបស់រាងកាយខាងក្នុងនៃយើងឲ្យបានច្បាស់ ហើយឲ្យល្អិតទៅទៀត។ នេះជាផ្លូវដែលត្រូវតែពិចារណាដើម្បីលះ មិនឲ្យជាប់ជំពាក់ក្នុងខន្ធទាំងប្រាំនេះ។ បើអាចលះនូវសេចក្តីប្រកាន់ខ្ជាប់ក្នុងរាងកាយនេះបាន ដូចជាយើងដកចេញបាននូវសេចក្តីទុក្ខព្រួយបានដែរ ពីព្រោះរបស់អស់ទាំងនេះហើយដែលបង្កើតនូវសេចក្តីទុក្ខព្រួយឲ្យមានឡើង។ ទុក្ខកើតឡើងបានដោយសារតែរឿងនេះ គឺ **ឧបាទានក្ខន្ធ** ដែលយើងប្រកាន់ថាជាតួខ្លួនរបស់យើងនេះហើយជាទុក្ខ។ បើយើងយល់តាមការពិតដូចនេះហើយ គឺការភាវនានេះ វានឹងអាចបន្ធូរបន្ថយនូវសេចក្តីទុក្ខព្រួយចេញបាន; ដូចជាយើងមួលខ្ចៅវិលទៅខាងឆ្វេងជានិច្ច វានឹងអាចធូរចេញមកបាន វាមិនណែន មិនតឹង មិនដូចជាយើងមួលទៅរកខាងស្តាំ។

បើកាលណាយើងមិនស្គាល់របស់ទាំងអស់នេះឲ្យច្បាស់ទេ វានឹងបង្វិលយើងឲ្យតឹងទៅជានិច្ច វិលទៅរកការរឹតរួតដល់ខ្លួនឯងវិញ នាំឲ្យទៅជាកើតទុក្ខគ្រប់បែបយ៉ាង ដោយសារតែសេចក្តីល្អអាក្រក់, មានលាភ អស់លាភ, បានយស ធ្លាក់យស, សេចក្តីសរសើរ និន្ទា, និងសេចក្តីសុខទុក្ខ ទាំងអស់នេះមិនខានឡើយ។ ទាំង ៨ យ៉ាងនេះហៅថា **លោកធម៌** ជាធម៌សម្រាប់លោក។

កាលណាយើងស្គាល់នូវរឿងទាំងនេះអស់ហើយ ក៏ដូចជាយើងបានបន្ធូរខ្ចៅចេញមកវិញ។ ក្នុងផ្លូវធម៌លោកហៅថាកើត **និព្វិទាញ្ញាណ** គឺសេចក្តីធុញទ្រាន់ ហើយបានស្រាយនូវសេចក្តីជាប់ជំពាក់និងសេចក្តីស្រលាញ់ចេញបាន; យើងនឹងអស់កង្វល់ ហើយនឹងបានទទួលនូវសេចក្តីសុខស្រួលជាពុំខានឡើយ។

មានឧទាហរណ៍ដូចជាក្បាលរបស់យើងនៅស្រុកខ្មែរយើងនេះ; ក្បាលជារបស់សំខាន់បំផុត ស្ទាបលេងមិនបានទេ។ បើសិនជាទៅស្ទាបក្បាលគ្នាលេងនៅតាមផ្លូវ មុខជារករឿងវាយគ្នាពុំខានឡើយ។ នេះមកពីមិនទាន់យល់ព្រម។ បើដូចជានាយទាហានមករកអាត្មា សូមឲ្យស្ដោះក្បាលឲ្យ;

អាត្មាចាប់ស្ទាបផ្លុំស្តោះឲ្យ គ្មានកើតរឿងហេតុអ្វីឡើយ, ស្ទាបបានដោយស្រួល គេកាន់តែមានចិត្តរីករាយថែមទៀតផង។ នេះមកពីគេព្រមឲ្យធ្វើមួយដងមួយកាល តែបើទៅស្ទាបនៅតាមផ្លូវវិញ មុខជាវាយគ្នាហើយ។ នេះហើយដែលជាទុក្ខ, ត្រង់នេះឯង ត្រង់ការប្រកាន់ជាប់ជំពាក់ត្រង់នេះឯងហើយ។

អាត្មាធ្លាប់ទៅបរទេស ឃើញគេចាប់ក្បាលគ្នាលេងដោយស្រួល; ទាំងស្រីទាំងប្រុសចាប់ក្បាលគ្នាទៅវិញទៅមក, គេសម្គាល់ថាជាការរាប់អានគ្នាទៅវិញផង។ នេះអំពីគេមិនប្រកាន់ មិនយកចិត្តទុកដាក់ជាមួយរបស់ហ្នឹង។ បើយើងលះបាន មិនប្រកាន់បានត្រឹមណា យើងបានទទួលនូវសេចក្តីសុខប៉ុននោះ។

បើនៅស្រុកយើង គេចាប់ក្បាលជង្គង់លេងមិនអីទេ ពីព្រោះខ្មែរយើងមិនមានប្រកាន់; ប៉ុន្តែបើចាប់ក្បាលវិញ មិនបានជាដាច់ខាត ពីព្រោះយើងសម្គាល់ថាជារបស់សំខាន់បំផុត។ នេះហើយមកពីយើងទាញយកទុកថាជារបស់យើង។ ការពិត ក្នុងរូបរាងកាយនៃយើងទាំងអស់នេះវាស្មើគ្នា ដូចគ្នាប្រហែលគ្នា មិនមានមួយណាធំជាងណាឡើយ; តែមកពីយើងប្រកាន់យកមកដាក់តម្លៃឲ្យពិតៗ។ មនុស្សយើងនេះជាប់ជំពាក់ត្រង់តែសេចក្តីប្រកាន់នេះធំណាស់។ កន្លែងនេះហើយដែលធ្វើឲ្យហេតុទៅជាទុក្ខកើតឡើង។ ដូចនេះ យើងត្រូវខំរំលត់ហេតុនេះចេញ កុំឲ្យមានឫសកើតឡើងបាន; កុំឲ្យមានទុក្ខកើតឡើងមានបានទៀត។ ដូចជាយើងពិចារណាក្នុងរាងកាយរបស់យើងថាមានស្មើគ្នាទាំងអស់, អំពីបាតជើងរហូតដល់ក្បាល មានសភាពប្រហែលគ្នា។

ដូចនេះ នៅពេលដែលមានគេមកស្ទាបក្បាលរបស់យើង ក៏មិនខុសអ្វីដែរ; នេះគឺដែលលះហេតុបាន។ មនុស្សយើងនេះមានហេតុតែប៉ុណ្ណឹងឯង គឺមានសេចក្តីជាប់ជំពាក់តែជាមួយនឹងរូបរាងកាយនេះឯង។ គ្មានរឿងអ្វីក្រៅពីនេះទេ។ រឿងក្នុងគ្រួសារ រឿងក្នុងប្រទេសជាតិ ក៏ដូចគ្នាដែរ; ខំច្បាំងគ្នា សម្លាប់គ្នា ហើយគ្មានឃើញអ្នកណាម្នាក់អាចយកអ្វីទៅជាមួយខ្លួនបានឡើយនៅពេលដែលស្លាប់ទៅនោះ។

ការមានអំណាច មានលាភ មានយស ការសរសើរ និន្ទា បានសុខទុក្ខ នេះជាលោកធម៌ ដែលគ្របសង្កត់នូវសត្វលោកឲ្យនៅ។ ដូចនេះ បានជាសត្វលោកវង្វេងក្នុងលោកធម៌នេះជាធំ ដ៏លាមកអាក្រក់, ជាធម៌នាំឲ្យមនុស្សមានសេចក្តីទុក្ខជានិច្ច។ បើយើងមិនបានភាវនា មិនបានពិចារណាឲ្យដឹងទាន់វាទេនោះ យើងត្រូវជាកើតទុក្ខព្រួយ ហើយអាចសម្លាប់គ្នា បៀតបៀនគ្នា ដោយសារតែពីរឿងលាភអំណាចនេះឯង។ តើពីព្រោះហេតុអ្វី? ពីព្រោះកាលណាយើងមិនបានភាវនា មិនបានពិចារណាឲ្យបានទៀងទាត់នោះទេ ចិត្តរបស់យើងតែងតែនឹកគិតទៅរករឿងនេះខ្លះ រឿងនោះខ្លះ; ជាពិសេសច្រើនតែទៅប្រមូលយកតែរឿងណាដែលពិបាក, ធ្វើឲ្យចិត្តបានខ្វល់ជានិច្ច។ ជួនកាលគិតចង់បាននូវរបស់ផ្សេងៗ ចង់បានឡើងបុណ្យស័ក្តិ ជាយ៉ាងនេះ ជាយ៉ាងនោះឡើង។ កាលណាមិនបានដូចសេចក្តីប្រាថ្នា ក៏តាំងមានចិត្តតឹង កើតទៅជាទុក្ខឡើង។

កាលពីដើម ធ្លាប់បានឮចាស់ទុំនិទានអំពីរឿងមេឃុំកំណាចឲ្យស្តាប់។ នៅពេលដែលគាត់បានឡើងបុណ្យជាមេឃុំ គាត់កើតសេចក្តីវង្វេងក្នុងបុណ្យស័ក្តិ។ មានមិត្តសម្លាញ់ចាស់ៗរបស់គាត់

ជាច្រើនបាននិយាយជាមួយនឹងគាត់លេងដូចកាលពីដើមមិនបានជាដាច់ខាត គឺគាត់ប្រាប់ដល់មិត្តទាំងនោះថា កុំឲ្យទៅជិតស្និទ្ធស្នាលដូចអំពីកាលមុនជាមួយនឹងគាត់ទៀត ពីព្រោះគាត់មិនដូចពីដើមទៀតឡើយ។

ការមានយស មានបុណ្យស័ក្តិក៏ដោយ មានលាភ ការសរសើរ បានសុខបានទុក្ខក៏ដោយ, ព្រះពុទ្ធអង្គបានទ្រង់ត្រាស់សំដែងថា ឲ្យស្គាល់របស់ទាំងនេះឲ្យបានច្បាស់លាស់។ ទុក្ខវានៅជារបស់ចាស់ដដែល, ទុកវាគ្រាន់តែប្រើនៅពេលមានកិច្ចការ បុណ្យទាន បានហើយ; ដល់ពេលចប់កិច្ចការពិធីនោះហើយ ទុកវាឲ្យនៅកន្លែងដើមវិញ, ជាមនុស្សដដែលវិញ។ បើកាលណាយើងមិនស្គាល់ឲ្យដល់ជម្រៅរបស់វានោះទេ គឺលាភ យស បុណ្យស័ក្តិ និងសេចក្តីសរសើរនិន្ទាទាំងអស់នេះ មុខជានឹងអាចធ្វើបាបគ្នាបាន មកតែអំពីការវង្វេងនូវអំណាចបុណ្យស័ក្តិនេះឯង។

កូនចៅ ញាតិមិត្តឯទៀតទាំងអស់, បើមានគំនិតយល់ត្រូវបានល្អដូចគ្នាហើយ ក៏គឺជាខ្សែស្រឡាយ ជាសាច់ឈាមជាមួយគ្នាទាំងអស់។ រឿងរ៉ាវផ្សេងៗទាំងពួងនោះ គ្រាន់តែជារឿងគេសន្មតឡើងពិតៗ ប៉ុន្តែប្រកបដោយកិលេសដ៏ធំ ដែលលោកហៅថា **លោកធម៌** នេះ។ សត្វលោកដែលនៅក្នុងលោកនេះ ច្រើនតែវង្វេងទៅតាមលោកធម៌នេះ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា រឿងទាំងឡាយទាំងពួងនេះ វាកើតមកក្រោយទេ។ ពេលមនុស្សយើងកើតមកជាដំបូង មានតែរូបនិងនាមកើតឡើងមកសោះ។ ដល់ពេលក្រោយមក យកនាយ "**ក**" មកដាក់ចូល, នេះជាការកើតឡើងដោយសន្មតិ។ ដល់តមកទៀតក៏មាន នាយចៅហ្វាយ, នាយករដ្ឋមន្ត្រីឡើងមក។ បើយើងមិនយល់ក្នុងរឿងនេះឲ្យបានច្បាស់ទេ យើងក៏យល់ថាជារបស់ពិត; ហើយក៏តាំងនាំគ្នាខំរែក ខំពន់ លីសែង យកមកទុក គឺខំស្គាយយកលាភ យស បុណ្យស័ក្តិ ឈ្មោះ សំឡេងមកទុកក្នុងខ្លួន; ហើយក៏នាំគ្នាប្រើអំណាចបុណ្យស័ក្តិនេះមកគំរាមដល់អ្នកទន់ខ្សោយ តូចជាងខ្លួន, អាចបញ្ជាឲ្យយកមនុស្សដូចគ្នា ដែលមិនមានកំហុស យកទៅធ្វើបាបក៏អាចបានដែរ គឺអាចប្រើឲ្យយកអ្នកនេះទៅដាក់គុក យកអ្នកនោះទៅសម្លាប់ ដូចនេះជាដើម។

កេរ្តិ៍យស, ពាក្យថាកេរ្តិ៍យសនេះហើយ ដែលជាតួ **ឧបាទាន**។ នៅពេលមានកេរ្តិ៍យសដល់មកក៏ចាប់ផ្តើមបញ្ជាយកតែម្តង, ខុសខ្លះត្រូវខ្លះ ចេះតែធ្វើទៅ ដោយអំណាចរបស់ខ្លួន ទៅតាមអារម្មណ៍នៃខ្លួន; យើងតាំងតែខំធ្វើតែសេចក្តីខុស អាក្រក់នេះជានិច្ចតរៀងទៅ បើឃ្លាតឆ្ងាយអំពីធម៌។

នេះជារឿងបដិបត្តិ; បើយើងបានដឹងយ៉ាងនេះហើយ ក៏មិនអាចប្រព្រឹត្តបែបខុសៗនេះឡើយ។ អំពើល្អនិងអាក្រក់នេះ មានមកតាំងតែពីដើមម្ល៉េះ។ ឯលាភ យស បុណ្យស័ក្តិ, បើបានទទួលមកហើយ ក៏ឲ្យមានត្រឹមតែ លាភ យស បុណ្យស័ក្តិនោះបានហើយ; កុំឲ្យវាចូលមកដល់ខ្លួនរបស់យើង, យកវាមកប្រើនៅក្នុងពេលការងារ ឬពិធីផ្សេងៗ រួចហើយក៏ហើយគ្នាទៅ, ឯខ្លួនយើងក៏នៅដូចពីកាលមុនដដែល។ កាលណាយើងបានភាវនានិងពិចារណាដល់រឿងនេះហើយ សូម្បីយើងបានទទួលរបស់ល្អវិសេសមក ក៏ឥតមានចិត្តត្រេកអរឡើយ; មិនវង្វេងជាមួយនឹងរបស់នោះទេ មានចិត្តស្មើ នឹងដូចដើម, មានលក្ខណៈដូចគ្នាទាំងអស់ គ្មានអ្វីប្លែកឡើយ។

រឿងនេះ ព្រះពុទ្ធជាម្ចាស់នៃយើងទ្រង់ត្រាស់ឲ្យនាំគ្នាខំពិចារណាដូច្នេះ ទើបបានយល់ការពិត

របស់វា។ កាលណាយើងបានរបស់អ្វីមក ក៏វាមិនអាចនាំចូលមកតាក់តែងដល់ចិត្តរបស់យើងបានឡើយ។ ដូចជាគេតែងតាំងឲ្យធ្វើជានាយកចៅហ្វាយធំមួយ យើងព្រមធ្វើ; ប៉ុន្តែចិត្តរបស់យើងកុំឲ្យទៅជាប់ជំពាក់ជាមួយថា នេះនោះ។ ទុកជាគេលើកឲ្យធ្វើជាស្មីក៏ដោយ ចិត្តរបស់យើងឲ្យនៅនឹង ដូចកាលពីដើមដដែល។ បើយើងគិតបាន ធ្វើបានតាមរបៀបនេះ ហើយយល់ពិតប្រាកដមែន, យើងទៅជាមនុស្សមិនវង្វេងក្នុងលោកធម៌។ គេចង់យករបស់អ្វីមកឲ្យ ក៏វាប៉ុណ្ណឹង; វាគ្រាន់តែជាសង្ខារ មិនអាចមានអ្វីចូលមកតាក់តែងដល់ចិត្តរបស់យើងបានទៀតឡើយ។ មិនអាចយកពណ៌មកច្របល់បានទៀតឡើយ។ ការជ្រលក់ចិត្តឲ្យកើត **រាគៈ ទោសៈ មោហៈ** នេះត្រូវអស់អំណាច, មិនអាចកើតបានជាដាច់ខាត។ កាលណាមិនមានរបស់ទាំងនោះហើយ ត្រូវមានមនុស្សជាច្រើនអាចជួយទ្រទ្រង់ព្រះពុទ្ធសាសនាបានដោយពិតប្រាកដ; ហើយពុទ្ធសាសនានឹងបានចម្រើនរុងរឿងជាមិនខានឡើយ។

សូមលោក-អ្នកដែលមានចិត្តជួយលើកតម្កើងព្រះពុទ្ធសាសនា ឬលោកអ្នកដែលនឹងតាំងចិត្តជួយក៏ដោយ, សូមឲ្យគិតពិចារណាក្នុងផ្លូវនេះឲ្យបានមែនទែន; ឲ្យមានសីលធម៌កើតក្នុងសន្តានចិត្តរបស់ខ្លួន។ បើសរុបសេចក្តីទៅថា ការជួយទ្រទ្រង់នូវព្រះពុទ្ធសាសនាដ៏ពិតប្រាកដនោះ ត្រូវធ្វើយ៉ាងនេះ គឺជួយផ្គត់ផ្គង់ដោយអាហារ កន្លែងនៅសំណាក់អាស្រ័យ ថ្នាំកែរោគ ក៏ជាការត្រូវម្យ៉ាងដែរ; ប៉ុន្តែវាត្រូវត្រឹមតែសម្បកខាងក្រៅ។ ដូចនេះ ទាយក ទាយិកាទាំងឡាយ ដែលបានអញ្ជើញមកស្តាប់ទេសនា បំពេញក្នុងការកុសលនេះ, សូមកុំភ្លេចរឿងនេះឲ្យសោះ។ ដើមឈើតែងមានសម្បក ស្រាវ ខ្លឹម, របស់ទាំងបីនេះតែងអាស្រ័យគ្នានឹងគ្នា ទើបអាចរស់នៅបាន។ មានខ្លឹមបានក៏ពីព្រោះអាស្រ័យនូវសម្បក, មានសម្បកបានដោយសារស្រាវ មានស្រាវបានក៏ដោយសារខ្លឹម។ ត្រូវអាស្រ័យគ្នាយ៉ាងនេះ ដូចជា **សីល សមាធិ** និង **បញ្ញា** ដែរ។ **សីល** គឺការពត់កាយវាចាឲ្យបានត្រឹមត្រូវ, ឯ **សមាធិ** គឺការពត់នូវចិត្តឲ្យនៅក្នុងអារម្មណ៍តែមួយ, **បញ្ញា** គឺការដឹងទូទៅនៃកងសង្ខារទាំងឡាយទាំងពួង។ ព្រះពុទ្ធអង្គទ្រង់ត្រាស់ឲ្យយើងរាល់គ្នា ខំនាំគ្នារៀនប្រតិបត្តិតាមផ្លូវនេះ ដែលហៅថា **បដិបត្តិបូជា**, ទើបបានឈ្មោះថាជាអ្នកជួយលើកតម្កើងព្រះពុទ្ធសាសនាយ៉ាងពិតប្រាកដមែនទែន។

បើកាលណាយើងមិនបានយករបស់ទាំងបីនេះមកប្រតិបត្តិឲ្យជាប់នៅក្នុងចិត្តរបស់យើងទេ នៅពេលបានលាភយើងអាចវង្វេងទៅតាមរបស់ទាំងនោះមិនខានឡើយ។

នៅពេលដែលយើងខំទំនុកបម្រុងតែរបស់ខាងក្រៅនេះហើយ បានជាការទាស់ទែងគ្នាច្រណែន ឈ្នានីស និងការព្យាបាទនៅមានបន្តទៅទៀត, មិនបានចប់ឡើយ។ ហើយក៏មានការចងពៀរជាមួយគ្នានឹងគ្នាតទៅទៀត; ការបាញ់កាប់ចាក់ក៏មិនមានពេលនឹងឈប់ដែរ។ មុននឹងឈប់នូវរឿងនេះបាន ត្រូវតែនាំគ្នាពិចារណានូវលោកធម៌ទាំង ៨ ប្រការនេះឲ្យបានហ្មត់ចត់ គឺ **ការបានលាភ ការអស់លាភ សេចក្តីល្អ សេចក្តីអាក្រក់ ការសរសើរ ការនិន្ទា សេចក្តីសុខ និងសេចក្តីទុក្ខ**។ ហើយពិចារណានូវគោលប្រតិបត្តិឲ្យមានសីល; ឲ្យនឹកគិតថា មនុស្សយើងក្នុងលោកនេះជាដុំតែមួយ, ឲ្យយល់ឃើញថា យើងក៏ដូចជាគេ គេក៏ដូចជាយើងដែរ, ក្នុងលោកនេះមានដុំតែមួយ គេបានសុខយើងក៏បានសុខ គេបានទទួលនូវទុក្ខយើងក៏បានទទួលនូវទុក្ខដែរ, ដូចគ្នា មានប្រហែលគ្នា។ យើងនាំគ្នាពិចារណាបានយល់យ៉ាងនេះហើយ, ទើបយើងមានសេចក្តីសប្បាយ កើតធម៌ឡើងបាន។ នេះជា

គោលនៃព្រះពុទ្ធសាសនា។

អ្នកដែលតាំងចិត្តជួយទំនុកបម្រុងក្នុងព្រះពុទ្ធសាសនា ត្រូវកាន់នូវសីល, បដិបត្តិសមាធិ, ហើយឲ្យមាននូវបញ្ញាជានិច្ច; គឺឲ្យឃើញថា របស់ទាំងពួងនៅក្នុងត្រៃលក្ខណ៍ទាំងអស់ គឺ **អនិច្ចំ** សេចក្តីមិនទៀត, **ទុក្ខំ** សេចក្តីទុក្ខ, **អនត្តា** សេចក្តីមិនមែនខ្លួនប្រាណ មិនមានអ្នកណាជាម្ចាស់ឲ្យបានរហូតឡើយ។ បើពិចារណាបានយ៉ាងនេះហើយ ទើបឈ្មោះថាជាអ្នកជួយទំនុកបម្រុងព្រះពុទ្ធសាសនាត្រូវពិតប្រាកដមែនៗ។ ចូរនាំគ្នាយកចំណុចនេះទៅគិត ទៅពិចារណាមើលទៀតទៅ។

ឱកាសដែលសម្តែងធម៌ដល់ញាតិញោមទាំងឡាយ ក៏សមគួរហើយ។ នៅទីបំផុតនេះ សូមឲ្យនាំគ្នាតាំងចិត្ត តាំងសតិ យកសេចក្តីទាំងនេះទៅពិចារណា, ហើយជួយទំនុកបម្រុង ដោយការប្រតិបត្តិយ៉ាងមុតមាំពិតប្រាកដគ្រប់ៗគ្នា។ សូមឲ្យបានជួបតែសេចក្តីសុខ-ចម្រើន គ្រប់ៗគ្នាកុំបីខានបែរទៅជាប្រការដទៃឡើយ។

ចប់ដោយសង្ខេបតែប៉ុណ្ណេះ។

※※※※※

**ដើរទៅក៏មិនមែន**
**ត្រឡប់មកក៏មិនមែន**
**ឈប់នៅក៏មិនមែន**

ធ្វើរួចនៅទីក្រុងលីយ៉ុង ថ្ងៃទី២៣ កក្កដា ២៥៣៣/១៩៩០

ជូនជី ចំរើន ចារ្យន ចារុវណ្ណោ

# ពាក្យរំឭកដល់កូនចៅ

កូនចៅប្រុសស្រី ចូរខំឃ្លាតខ្ចី រៀនអក្សរខ្មែរ
ឲ្យបានគ្រប់គ្នា ដើម្បីរក្សា ព្រះពុទ្ធសាសនា
ឲ្យបានចម្រើន។

ពាក្យចាស់ពោលថា បើគ្មានសាសនា បានទុក្ខវេទនា
មិនយល់ខុសត្រូវ ទៅជាលីលា មិនស្គាល់មីងមា
ឪពុកម្តាយឯង។

ហេតុនេះចៅអើយ អ្នកកុំកន្តើយ ខំប្រឹងស្វះស្វែង
កុំឲ្យបំភ្លេច នូវភាសាយើង ទុកបានថ្កុំថ្កើង
ដល់ប្អូនក្រោយៗ។

អ្នកប្រាជ្ញបុរាណ លោកបានទូន្មាន ថាកុំបណ្តោយ
ចេះឲ្យប្រាកដ កុំឲ្យលោយធោយ កាលណាយើងខ្សោយ
រលាយមិនខាន។

ចាំឲ្យហ្មត់ចត់ បានវិញងាយៗ តែជាតិរលាយ
ឈ្មោះខ្មែររលត់។

រៀបរៀងដោយដូនជី ចំរើន ចារុវណ្ណា